# ស្វែងយល់ពីពិធីបុណ្យចូលឆ្នាំថ្មីប្រពៃណីជាតិខ្មែរ
# ឆ្នាំរោង ឆ្នាំ២០២៤

*ដោយៈ **បណ្ឌិត ជា វណ្ណី***

*ប្រធាននាយកដ្ឋានធម្មសាស្ត្រ ចរិយាសាស្ត្រ និងយេនឌ័រ*

*នៃវិទ្យាស្ថានមនុស្សសាស្ត្រនិងវិទ្យាសាស្ត្រសង្គម*

*នៃរាជបណ្ឌិត្យសភាកម្ពុជា*

*នៅលើលើកយើងនេះ មិនថាប្រទេសណាជាប្រទេសណាទេ គឺគ្រប់ជាតិសាសន៍ទាំងអស់ តែងតែមានការប្រារព្ធពិធីចូលបុណ្យឆ្នាំថ្មីដែលជាប្រពៃណីរបស់ប្រជាជាតិរៀងៗខ្លួន គ្រាន់តែថាគេនិយមកំណត់ពេលវេលានៃការរៀបចំបុណ្យនេះផ្សេងៗគ្នា ដោយស្របទៅតាមជំនឿទំនៀមទម្លាប់និងប្រពៃណីរបស់គេប៉ុណ្ណោះ។*

*យ៉ាងណាមិញជនជាតិខ្មែរយើងក៏បានប្រារព្ធធ្វើពិធីបុណ្យចូលឆ្នាំតាំងពីបុរាណកាលជារៀងរាល់ឆ្នាំរហូតមក ដ្បិតពិធីបុណ្យនេះជាពិធីបុណ្យប្រពៃណីជាតិដ៏ធំមួយដែលដក់ជាប់ក្នុងចិត្ត និងជីវភាពប្រជាពលរដ្ឋខ្មែរតាំងពីយូរលង់មកហើយ ដែលពិធីបុណ្យនេះមិនមែនចេះតែប្រារព្ធធ្វើឡើងនៅពេលវេលាណាក៏បាននោះទេ គឺប្រវត្តិសាស្ត្រនិងកាលវេលានៃពិធីបុណ្យចូលឆ្នាំត្រូវបានបុព្វបុរសខ្មែរកំណត់យ៉ាងជាក់លាក់និងត្រឹមត្រូវ។*

## ១. ពេលវេលាចូលឆ្នាំខ្មែរ

*ពិធីបុណ្យចូលឆ្នាំថ្មីប្រពៃណីជាតិខ្មែរនាឆ្នាំនេះ គឺត្រូវនឹងថ្ងៃសៅរ៍ ៥កើត ខែចេត្រ ឆ្នាំរោង ឆស័ក ពុទ្ធស័ករាជ២៥៦៧ ត្រូវនឹងថ្ងៃទី១៣ ១៤ ១៥ ១៦ ខែមេសា ឆ្នាំ២០២៤ (វេលាម៉ោង១០និង១៧នាទីយប់) ជាសរុបចំនួន៤ គឺថ្ងៃទី**១៣** ជាថ្ងៃ**មហាសង្ក្រាន្ត** ថ្ងៃទី**១៤ ១៥** ជាថ្ងៃ**វិរៈវ័នបត** និងថ្ងៃទី**១៦** ជាថ្ងៃ**ឡើងស័ក**។*

*កាលដើមឡើយប្រទេសខ្មែរប្រារព្ធធ្វើបុណ្យចូលឆ្នាំនៅក្នុងខែ**មិគសិរ** ព្រោះដូនតាខ្មែរកំណត់យកខែនេះជាខែដើមឆ្នាំ។ កាលពីសម័យដើម ឆ្នាំនីមួយៗចែកចេញជាបីរដូវគឺ **ហេមន្តរដូវ គិម្ហរដូវ** និង**វស្សានរដូវ**។ បុរាណាចារ្យលោកគិតថា **ហេមន្តរដូវ** ជារដូវត្រជាក់*

ត្រូវចាត់ទុកជា**ដើមឆ្នាំ** ដែលប្រៀបបាននឹងពេលព្រឹកផុតពីរាត្រី គឺជា**ដើមថ្ងៃ**។ **គិម្ហរដូវ**ជា**រដូវក្ដៅ** ត្រូវចាត់ទុកជា**កណ្ដាលឆ្នាំ** ប្រៀបដូចជា **ពេលថ្ងៃត្រង់**។ ចំណែកឯ **វស្សានរដូវ**ជារដូវដែលមេឃមីរងងឹតមានភ្លៀងផ្គរ ត្រូវចាត់ទុកជា**ចុងឆ្នាំ** ប្រៀបបាននឹង**ពេលយប់**។

បើតាមអត្ថបទរបស់លោក **ជីវ តាក្វាន់**[1] ខ្មែរយើងបានប្រារព្ធពិធីបុណ្យនៅក្នុងខែចេត្រ ដោយមានល្បែងចោលឈូងផង និងមានទទួលទឹកមន្តព្រះពុទ្ធពីគ្រប់ទីកន្លែងក្នុងអាណាចក្រ។ ក្រៅពីនេះ យើងមានសិលាចារឹកមួយនៅប្រាសាទព្រះខ័ន បញ្ជាក់ថា នៅថ្ងៃទី១៤ និង១៥កើត ខែចេត្រ ក៏មានប្រារព្ធពិធីបុណ្យមួយដូចបានរៀបរាប់ខាងលើ ហើយទោះបីជាឯកសារទាំងពីរពុំបានចែងថា ពិធីបុណ្យខាងលើនេះមានឈ្មោះហៅថា បុណ្យចូលឆ្នាំក៏ដោយ ក៏តាមរយៈនៃឯកសារទាំងនេះ យើងអាចសន្និដ្ឋានបានថា តាំងពីបុរាណកាលមក ខ្មែរយើងតែងតែមានប្រារព្ធធ្វើពិធីបុណ្យយ៉ាងសំខាន់នៅក្នុងខែចេត្រ។

## ២. ប្រវត្តិនៃពិធីបុណ្យចូលឆ្នាំខ្មែរ

នៅដើមនៃភទ្ទកប្ប មាន**សេដ្ឋី**ម្នាក់មានបុត្រមួយឈ្មោះ**ធម្មបាលកុមារ** ជាអ្នកមានចំណេះវិជ្ជាដ៏វិសេស បានរៀនចេះចប់**គម្ពីរត្រៃវេទ** តាំងពីអាយុបាន**៧ឆ្នាំ**។ **សេដ្ឋីបិតា**បានសាងប្រាសាទឱ្យធម្មបាល នៅទៀបដើមជ្រៃមួយដើមធំ នៅឆ្នេរទន្លេ ដែលជាទីស្នាក់អាស្រ័យនៃបក្សីទាំងឡាយ។ ធម្មបាលចេះទាំងភាសាបក្សាបក្សីទាំងពួងផង ព្រមទាំងអាចធ្វើជាអាចារ្យសម្ដែងមង្គលផ្សេងៗដល់មនុស្សទាំងពួងផង។

គ្រានោះ មនុស្សលោករមែងរាប់អាន**មហាព្រហ្ម** និង**កបិលមហាព្រហ្ម**១អង្គទៀត ដែលជាអ្នកសម្ដែងមង្គលដល់មនុស្សទាំងពួង។ ពេលនោះកបិលមហាព្រហ្មជ្រាបព័ត៌មាននេះក៏ចុះមកល្បងបញ្ហានឹងធម្មបាលចំនួន៣ប្រស្នា ដោយសន្យាថា ប្រសិនបើធម្មបាលអាចដោះប្រស្នាបាន នោះកបិលមហាព្រហ្មនឹងកាត់ព្រះសិរសាទ្រង់ដើម្បីបូជាចំពោះធម្មបាល ប៉ុន្តែប្រសិនបើធម្មបាលចាញ់ កបិលមហាព្រហ្មនឹងកាត់ក្បាលធម្មបាលវិញ។

កាលនោះ ធម្មបាលបានសុំឱ្យពន្យារពេលចំនួន៧ថ្ងៃ ដើម្បីគិតប្រស្នានេះ។ លុះកន្លងទៅបាន៦ថ្ងៃហើយ ធម្មបាលនៅតែគិតមិនឃើញចម្លើយ និងដឹងខ្លួនថា ព្រឹកនេះច្បាស់ជានឹងត្រូវស្លាប់ដោយអាជ្ញា កបិលមហាព្រហ្មជាប្រាកដ ធម្មបាលក៏សម្រេចចិត្ត

[1] ជីវ តាក្វាន់ បានដល់ទឹកខ្មែរនាឆ្នាំ១២៩៧។

រត់ទៅលាក់ខ្លួនពួនអាត្មាឱ្យស្លាប់ដោយខ្លួនឯង វាប្រសើរជាង។ គិតហើយ ធម្មបាលបានចុះពីប្រាសាទទៅពួននៅក្រោមដើមត្នោតមួយគូ។ ចៃដន្យនៅលើដើមត្នោតនោះ មានសត្វឥន្ទ្រីញីឈ្មោល១គូ ធ្វើសំបុកអាស្រ័យនៅទីនោះ។ វេលាយប់ **សត្វឥន្ទ្រីញី** សួរសត្វ**ឥន្ទ្រីឈ្មោល** ថា ព្រឹកនេះយើងបានអាហារអ្វីធ្វើជាចំណី? ឥន្ទ្រីឈ្មោលឆ្លើយថា យើងនឹងស៊ីសាច់ធម្មបាលកុមារ ដែលនឹងត្រូវកបិលមហាព្រហ្មសម្លាប់ ព្រោះធម្មបាលដោះប្រស្នានោះមិនរួចទេ។

ឥន្ទ្រីញីសួរថា ប្រស្នានោះដូចម្ដេច? ឥន្ទ្រីឈ្មោលឆ្លើយថា **វេលាព្រឹក** សិរីសួស្ដីស្ថិតនៅត្រង់ណា? ត្រូវឆ្លើយថា **នៅលើផ្ទៃមុខ** ហេតុនេះទើបមនុស្សទាំងឡាយត្រូវយកទឹកលប់មុខ។ ប្រស្នាទី២ ចោទថា **ថ្ងៃត្រង់** សិរីស្ថិតនៅត្រង់ណា? ត្រូវឆ្លើយថា **នៅលើទ្រូង** ហេតុនោះទើបមនុស្សត្រូវយកទឹកលាងទ្រូង។ ប្រស្នាទី៣ ចោទថា **វេលាល្ងាច** សិរីស្ថិតនៅត្រង់ណា? ត្រូវឆ្លើយថា **នៅនឹងជើង** ហេតុនោះហើយទើបមនុស្សទាំងឡាយត្រូវយកទឹកលាងជើង។ ធម្មបាលបានឮដូច្នេះ ក៏ត្រឡប់ទៅប្រាសាទវិញ។ លុះព្រឹកឡើង កបិលមហាព្រហ្ម ក៏មកសួរចម្លើយពីធម្មបាល។ ធម្មបាល ឆ្លើយដោះប្រស្នាតាមដែលបានឮ ហើយកបិល មហាព្រហ្មក៏ទទួលថា ពិតជាត្រឹមត្រូវ និងព្រមចុះចាញ់ ដោយសុខចិត្តធ្វើតាមពាក្យសន្យារបស់ខ្លួន។

កបិលមហាព្រហ្ម ហៅទេពធីតាទាំង៧អង្គជាបុត្រីមកប្រាប់ថា ឥឡូវបិតាត្រូវកាត់ព្រះសិរសា ដើម្បីបូជាចំពោះធម្មបាល តែបើដាក់ក្បាលនោះលើផែនដី នោះនឹងកើតជាភ្លើងឆេះទាំងលោកធាតុ បើបោះទៅលើអាកាស នឹងនាំឱ្យរាំងភ្លៀង បើចោលក្នុងមហាសមុទ្រ នោះទឹកនឹងរីងស្ងួតហួតអស់។ ដូច្នេះសូមឱ្យកូនទាំង៧អង្គ យកពានមកទទួលព្រះសិរសាបិតា។ ពោលរួច ព្រះអង្គក៏កាត់ព្រះសិរសាហុចទៅឱ្យព្រះនាងទុង្សា ជាបុត្រីច្បង។ ព្រះនាងទុង្សា ក៏បានយកពានមកទទួលព្រះសិរសាបិតា រួចហែប្រទក្សិណភ្នំព្រះសុមេរុចំនួន៦០នាទី ទើបយាងទៅប្រតិស្ឋានទុកក្នុងមណ្ឌលនៃគុហាគន្ធមាលី នាភ្នំកៃលាស និងបូជាគ្រឿង ទិព្វផ្សេងៗ។ កាលនោះព្រះ**វិស្សកម្មទេវបុត្រ** ក៏និមិត្ត**រោងទិព្វ**ធ្វើពី**កែវ៧ប្រការ** ឈ្មោះថា "**ភគវតីសភាសាលា**" ឱ្យជាទីប្រជុំនៃទេវតា។

លុះដល់គម្រប់១ឆ្នាំជាសង្ក្រាន្ត ទេពធីតាទាំង៧អង្គ ក៏ផ្លាស់វេនគ្នា មកអញ្ជើញព្រះសិរសាកបិល មហាព្រហ្ម ចេញមកហែប្រទក្សិណភ្នំព្រះសុមេរុជារៀងរាល់ៗឆ្នាំ រួចហើយយាងត្រឡប់ទៅស្ថានទេវលោកដើម្បីយកទៅតម្កល់វិញ។

ដោយមាននិទានបែបនេះហើយ ទើបខ្មែរយើងមានជំនឿ ហើយបានរៀបចំជាពិធីបូជាទេវតាដែលត្រូវវេនដង្ហែក្បាលកបិលមហាព្រហ្ម និងត្រូវអភិបាលពិភពលោករៀងរាល់ឆ្នាំថ្មីចូលមកដល់ពុំដែលអាក់ខានឡើយ ហើយកិរិយាជិះជំនិះ គឺ**ពេលព្រឹកគង់ឈរលើខ្នង ពេលថ្ងៃគង់អង្គុយពាក់ចៀង ពេលយប់ផ្ទុំ(ដេក)បើកភ្នែក និងធ្មេញចភ្នែកពីកណ្ដាលអាជ្រាត្រ។**

១. បើសង្ក្រានចំថ្ងៃ**អាទិត្យ** ត្រូវវេននាង**ទុង្សាទេវី** សម្លៀកបំពាក់ពណ៌ក្រហម សៀតផ្កាទទឹម គ្រឿងប្រដាប់បទុមរាគ ភក្សាហារផ្លែឧទុម្ពរ(ល្វា) ព្រហស្តស្តាំកាន់កង់ចក្រ ព្រះហស្តឆ្វេងកាន់ស័ង្ខ និងមានពាហនៈគ្រុឌ។

២. បើសង្ក្រានត្រូវចំថ្ងៃ**ច័ន្ទ** ត្រូវវេននាង**គោរាគៈទេវី** សម្លៀកបំពាក់ពណ៌លឿង សៀតផ្កាអង្គាបុស្ប គ្រឿងប្រដាប់មុក្តា (គជ់ខ្យង) ភក្សាហារប្រេង ព្រហស្តស្តាំកាន់ព្រះខ័ន ព្រះហស្តឆ្វេងកាន់ឈើច្រត់ និងមានពាហនៈព្យគ្ឃ(ខ្លា)។

៣. បើសង្ក្រានត្រូវចំថ្ងៃ**អង្គារ** ត្រូវវេននាង**រាក្សសាទេវី** សម្លៀកបំពាក់ខ្មៅ សៀតផ្កាឈូក គ្រឿងប្រដាប់មោរា ភក្សាហារលោហិត ព្រហស្តស្តាំកាន់ត្រីសូល៍ ព្រះហស្តឆ្វេងកាន់ធ្នូនិងពាហនៈអស្សតរៈ។

៤. បើសង្ក្រានត្រូវចំថ្ងៃ**ពុធ** ត្រូវវេននាង**មណ្ឌាទេវី** សម្លៀកបំពាក់ផ្ទៃមេឃ សៀតផ្កាចំប៉ា គ្រឿងប្រដាប់ពិទូរ្យ ភក្សាហារទឹកដោះ ព្រហស្តស្តាំកាន់ម្ជុល ឆ្វេងកាន់ឈើច្រត់ និងមានពាហនៈលា។

៥. បើសង្ក្រានត្រូវចំថ្ងៃ**ព្រហស្បត៍** ត្រូវវេននាង**កិរិណីទេវី** សម្លៀកបំពាក់បៃតង សៀត ផ្កាមណ្ឌា គ្រឿងប្រដាប់មរកត ភក្សាហារ សណ្ដែក ល្ង ព្រហស្តស្តាំកាន់កង្វេរ ព្រះហស្តឆ្វេងកាន់ធ្នូ និងមានពាហនៈដំរី។

៦. បើសង្ក្រានត្រូវចំថ្ងៃ**សុក្រ** ត្រូវវេននាង**កិមិរាទេវី** សម្លៀកបំពាក់ស សៀតផ្កាចង្កុលណី(ប្រភេទពួកឈូកមានច្រើនស្រទាប់) គ្រឿងប្រដាប់បុស្បរាគ័ម(ថ្មើមថ្ម) ភក្សាហារចេកណាំវ៉ា ព្រហស្តស្តាំកាន់ព្រះខ័ន ព្រះហស្តឆ្វេងកាន់ពិណ និងមានពាហនៈក្របី។

៧. បើសង្ក្រានត្រូវចំថ្ងៃ**សៅរ៍ ត្រូវវេន**នាងម**ហោទរាទេវី** សម្លៀកបំពាក់ខៀវចាស់ សៀត ផ្កាត្រកៀត គ្រឿងប្រដាប់នីលរតន៍ ភក្សាហារសាច់ទ្រាយ ព្រហស្តស្តាំកាន់ចក្រ ព្រះហស្តឆ្វេងកាន់ត្រីសូល៍ និងមានពាហនៈក្ងោក។

## ៣. ទំនៀមចូលឆ្នាំ

ជាទូទៅទំនៀមពិធីចូលឆ្នាំប្រព្រឹត្តទៅចំនួន**៣ថ្ងៃ**។ ថ្ងៃដំបូងជា**ថ្ងៃមហាសង្រ្កាន្ត** **ថ្ងៃទី២**ជាថ្ងៃ**វិរៈវ័នបត** និង**ថ្ងៃទី៣** ជា**ថ្ងៃឡើងស័ក**។ រីឯការកំណត់ខែ ថ្ងៃ ម៉ោង នាទី ដែលឆ្នាំចាស់ត្រូវផុតកំណត់ ហើយទេព្តាឆ្នាំថ្មីត្រូវចុះមកទទួលតំណែងពីទេព្តាឆ្នាំចាស់នោះ គេអាចដឹងបានដោយប្រើក្បួនហោរាសាស្រ្តបុរាណ គឺក្បួនមហាសង្រ្កាន្ត ហើយនៅសល់តែប៉ុន្មានថ្ងៃទៀតប៉ុណ្ណោះ ពិធីបុណ្យចូលឆ្នាំថ្មីប្រពៃណីជាតិខ្មែរនឹងចូលមកដល់។ តាមមហាសង្រ្កាន្តឆ្នាំនេះ ចូលឆ្នាំរោង ឆស័ក ពុទ្ធសករាជ២៥៦៨ គ.ស.២០២៤។ ដោយឡែកបុណ្យចូលឆ្នាំឆ្នាំនេះប្រព្រឹត្តទៅរយៈពេល**បួនថ្ងៃ** គឺនៅថ្ងៃ ៥កើត ៦កើត ៧កើត និង៨កើត ខែចេត្រ ត្រូវនឹង**ថ្ងៃសៅរ៍ ទី១៣** ខែមេសា វេលាម៉ោង២២និង១៧នាទី (**ថ្ងៃមហាសង្រ្កាន**) **អាទិត្យទី១៤** និង**ចន្ទទី១៥** (**ថ្ងៃវីរវ័នបត**) និង**អង្គារ៍ទី១៦** (**ថ្ងៃវីរៈឡើងស័ក**)។

. ពេលមុនចូលឆ្នាំ គេនាំគ្នាប្រុងប្រៀបរកស្បៀងអាហារ សំអាតផ្ទះសម្បែង រែកទឹកដាក់ពាង រកឧសទុក និងកាត់សំលៀកបំពាក់ថ្មីៗជាដើម។

. ថ្ងៃចូលឆ្នាំមកដល់ គេរៀបគ្រឿងសក្ការៈបូជាសម្រាប់ទទួលទេវតាឆ្នាំថ្មីមាន៖ បាយសី១គូ ស្លាធម៌១គូ ធូប៥ ទៀន៥ ទឹកអប់១គូ ផ្កាភ្ញី លាជ ទឹក១ផ្តិល ភេសជ្ជៈ នំចំណីនិងផ្លែឈើច្រើនមុខៗចំណែកផ្ទះសម្បែង គេតុបតែងរំលេចដោយអំពូលអគ្គិសនីខ្សែតូចៗចម្រុះពណ៌ ឬចង្កៀងគោមគ្រប់ពណ៌សម្រាប់ទទួលទេព្តាថ្មី។

. លុះដល់វេលាកំណត់ ទេព្តាឆ្នាំថ្មីយាងមក គេនាំកូនចៅអង្គុយជុំគ្នា អង្គុយនៅកន្លែងរៀបគ្រឿងសក្ការៈនោះ ហើយអុជទៀន ធូប បាញ់ទឹកអប់ បន់ស្រន់ សុំសេចក្តីសុខចម្រើន គ្រប់ប្រការ ពីទេព្តាឆ្នាំថ្មី។ ចំពោះគ្រឿងសក្ការៈ និងក្រយាស្ងោយដាក់ថ្វាយទេព្តានោះ គេនិយមតម្រូវតាមចិត្តទេវតាដែលនឹងចុះក្នុងឆ្នាំនីមួយៗ។ ឧទាហរណ៍៖ ឆ្នាំនេះទេវតាដែលត្រូវចុះមកនោះ គឺថ្ងៃសៅរ៍ត្រូវចំព្រះនាងមណ្ឌាទេវី សោយសាច់ទ្រាយគេអាចដាក់សាច់ទ្រាយថ្វាយ (តែបើមិនមានយើងអាចផ្លាយជផ្លាយផ្សេងៗបាន)។

. ពិធីទាំង៣ថ្ងៃ នៃថ្ងៃចូលឆ្នាំ

**ថ្ងៃទី១**៖ គេយកចង្ហាន់ទៅប្រគេនភិក្ខុទាំងឡាយនៅតាមវត្តអារាម។ ពេលល្ងាច គេនាំគ្នាជញ្ជូនខ្សាច់សាងវាលុកចេតិយដែលមាននៅជុំវិញព្រះវិហារ ឬនៅជុំវិញដើមពោធិ៍ណាមួយនៅក្នុងវត្តនោះ។ នៅពេលព្រលប់គេប្រគេនភេសជ្ជៈដល់ភិក្ខុ និមន្តភិក្ខុសូត្រចម្រើនព្រះបរិត្ត និងសំដែងធម៌ទេសនា។

***ថ្ងៃទី២៖*** កូនចៅជូនសម្លៀកបំពាក់ នំចំណី លុយកាក់ ដល់អ្នកមានគុណ មានឪពុកម្តាយ ជីដូនជីតា ជាដើម។ ជូនកាលគេធ្វើទានដល់មនុស្សបម្រើ ឬអ្នកក្រីក្រទៀតផង។ ពេលរសៀល គេនាំគ្នាទៅពូនភ្នំខ្សាច់ទៀត ហើយសូត្រធម៌អធិដ្ឋានភ្នំខ្សាច់ដែលគេសន្មត់ទុកដូចចូឡាមនីចេតិយ ហើយនិមន្តភិក្ខុបង្សុកូលចេតិយ បញ្ជូនមគ្គផលដល់វិញ្ញាណក្ខន្ធបងប្អូនដែលបានចែកឋានទៅ។

***ថ្ងៃទី៣៖*** ពេលព្រឹកនិមន្តភិក្ខុសូត្រឆ្លងភ្នំខ្សាច់។ ពេលល្ងាច និមន្តភិក្ខុស្រង់ទឹក និងស្រង់ព្រះពុទ្ធរូប (តាមការនិយមនៃស្រុកខ្លះ)។ នៅក្នុងឱកាសបុណ្យចូលឆ្នាំថ្មីនេះ គេនាំគ្នាលេងល្បែងប្រជាប្រិយកម្សាន្តសប្បាយជាច្រើន ដូចជាលេង បោះអង្គុញ ចោលឈូង ទាញព្រ័ត្រ លាក់កន្សែង ដណ្តើមស្លឹកឈើ ស្តេចចង់ ឱបត្រឡាច ចាប់កូនខ្លែង ជាដើម និង មានរបាំត្រុដិ (ច្រើនមាននៅខេត្តបាត់ដំបង សៀមរាប) ជាពិសេសទៀតគឺរាំវង់ អាស្រ័យទៅតាមការនិយមចូលចិត្តរបស់បុគ្គលម្នាក់ៗ ហើយអ្នកខ្លះក៏និយមនាំគ្នាដើរកម្សាន្តតាមរមណីយដ្ឋាន អ្នកខ្លះនិយមធ្វើបុណ្យទានតាមវត្តអារាមនានា។

## ៤.អត្ថន័យនៃពិធីបុណ្យចូលឆ្នាំ

ឆ្នាំចាស់បានកន្លងផុតទៅ ឆ្នាំថ្មីបានឈានចូលមកដល់ ជាគតិឱ្យយើងពិចារណានូវធម៌សង្វេកថា ពេលវេលាចេះតែកន្លងទៅជារៀងរាល់ឆ្នាំ ហើយអាយុកាលរបស់យើងគ្រប់គ្នាក៏អស់ទៅតាមឆ្នាំចាស់ដែលបានរសាត់បាត់ទៅ ដូច្នេះយើងមិនគួរប្រមាថ មិនគួរប្រព្រឹត្តិអាក្រក់ មិនគួរឈ្លោះទាស់ទែងខ្វែងគំនិតគ្នា មិនគួរប្រកួតប្រជែងគ្នា មិនគួរលោភលន់ មិនគួរកាប់សម្លាប់គ្នា ឬដណ្តើមគ្នារស់នោះទេ គួរតែយើងចេះចែកគ្នារស់ លះបង់នូវ ទង្វើអាក្រក់ ប្រព្រឹត្តិតែទង្វើល្អ បណ្តុះនូវព្រហ្មវិហារធម៌ សាមគ្គីធម៌ នៅក្នុងដួងចិត្តប្រកបដោយក្តីមេត្តា ករុណា កតញ្ញូតា ឧបត្ថម្ភដល់ជីដូនជីតាមាតាបិតា ក៏ដូចជាព្រះសង្ឃ និងចែករំលែកទានដល់ជនដែលមានការខ្វះខាត ទីទាល់ក្រ ដែលជាទុរគតជន ក៏ដូចជាអ្នកកំព្រើកំព្រាគ្មានទីពឹងប្រកបដោយក្តីអាណិតអាសូរ។

ដើម្បីអបអរសាទរចំពោះមរតកកេរដំណែលរបស់បុព្វការីជន ក៏ដូចជាឱ្យចេះថែរក្សាការពារនូវប្រពៃណី ទំនៀមទម្លាប់នៃពិធីបុណ្យចូលឆ្នាំ របាំនិងល្បែងប្រជាប្រិយ កុំឱ្យបាត់បង់ដោយប្រការផ្សេងៗ។

ដើម្បីបង្ហាញពីភាពសប្បាយរីករាយរបស់ប្រជាជនខ្មែរ បន្ទាប់ពីប្រមូលផលរួច ក៏

ដូចជាអបអរសាទរចំពោះធម្មជាតិ និង ផលិតផលកសិកម្មដោយបណ្តុះនូវក្តីសង្ឃឹម នាឆ្នាំបន្តៗទៀត។

ដើម្បីឧទ្ទិសបុណ្យកុសលដល់បុព្វការីជន មាតាបិតា ជីដូនជីតា ញាតកាសាច់សាលោហិត មិត្តសម្លាញ់ និងសព្វសត្វទាំងអស់ ដែលបានចែកឋានទៅ និងដើម្បីបានសេចក្តីសុខចម្រើនសម្រាប់ខ្លួនឯង សម្រាប់ក្រុមគ្រួសារនិងសង្គមជាតិ ទាំងបច្ចុប្បន្នកាលនិងអនាគតកាល។

## ៥. ស្វែងយល់ពីល្បែងប្រជាប្រិយមួយចំនួន និងរបាំត្រុដិក្នុងទំនៀមចូលឆ្នាំ

ល្បែងប្រជាប្រិយជាទូទៅគេច្រើនតែលេងនៅក្នុងពិធីបុណ្យចូលឆ្នាំថ្មីប្រពៃណីជាតិ។ ចូលឆ្នាំខ្មែរ គឺជាពិធីបុណ្យចូលឆ្នាំថ្មីរបស់កម្ពុជា ដែលកំណត់តាមប្រតិទិនពុទ្ធសាសនា តាមដំណើរគោចររបស់ព្រះចន្ទ ដែលរាប់តាមរង្វាស់នៃឆ្នាំចន្ទគតិ នៅក្នុងវប្បធម៌ខ្មែរ។ ពិធីបុណ្យនេះត្រូវបានគេហៅថា **ពិធីបុណ្យគិម្ហៈរដូវ** "បុណ្យរដូវក្តៅ" នៃវិស្សមកាលតូច ដែលបានមកពីអរិយធម៌នៃវប្បធម៌ប្រទេសឥណ្ឌា ដែលហៅថ្ងៃចូលឆ្នាំថ្មីថា "**សង្ក្រាន្ត**" (Sangkranta)។ ពាក្យ **សង្ក្រាន្ត** ជាភាសាដើមនៃពាក្យ (សំស្ក្រឹត) ដែលប្រជាជនខ្មែរឱ្យនិយមន័យថា (សង្ក្រាន្តខ្មែរ)។ សង្ក្រាន្ត គឺជាថ្ងៃចូលឆ្នាំថ្មី ដែលប្រារព្ធឡើងរៀងរាល់ថ្ងៃទី១៣ឬថ្ងៃទី១៤ ខែមេសា ជារៀងរាល់ឆ្នាំ ដែលប្រជាពលរដ្ឋខ្មែរគ្រប់រូបឈប់សម្រាកពីការងារដើម្បីចូលរួមអបអរថ្ងៃចូលឆ្នាំថ្មី។ ជាទូទៅមុនថ្ងៃចូលឆ្នាំខ្មែរមកដល់ ប្រជាជនខ្មែរគ្រប់រូបនឹងធ្វើដំណើរនិវត្តពីគ្រប់ទិសទីមកស្រុកកំណើតរបស់ខ្លួនវិញ ដើម្បីជួបជុំក្រុមគ្រួសាររៀងរាល់មួយឆ្នាំម្តង។ នៅមុនថ្ងៃចូលឆ្នាំ ប្រជាជនខ្មែរតែងតែរៀបចំសម្អាតនិងតុបតែងលម្អផ្ទះសម្បែង ដោយផ្ទះខ្លះក៏ព្យួរគោមផ្កាយ ផ្ទះខ្លះក៏ដាក់ភ្លើងពណ៌ ដែលគេមានជំនឿថា ពន្លឺគោមផ្កាយនិងភ្លើងពណ៌ទាំងនោះ នឹងនាំមកនូវសិរីសួស្តី លាភសំណាង និងភាពមានបានផងដែរ។ ក្រៅពីនេះទៀតមានលេងល្បែងកម្សាន្តប្រជាប្រិយខ្មែរនៅតាមភូមិស្រុករបស់ពួកគេផងដែរ ដូចជា៖ *ចោលឈូង បោះអង្គុញ លាក់កន្សែង ទាញព្រ័ត្រ ស្តេចចង់ វាយក្អម ដណ្តើមស្លឹកឈើ ក្លែងចាប់កូនមាន់* ជាដើម ហើយក្រៅពីល្បែងកម្សាន្តទាំងនេះ ក៏នៅមានលេងល្បែងកម្សាន្តមួយប្រភេទទៀតហៅថា ពិធីលេងជះទឹក តាមទីលំនៅនីមួយៗ តែងមានធុងទឹកនៅពីមុខផ្ទះរបស់ពួកគេ ដើម្បីជះទឹកទៅលើអ្នកដំណើរ ដែលពួកគេមានជំនឿថា ភាពមិនល្អដែលតោងទាមយើងគ្រប់គ្នាតាំងពីឆ្នាំចាស់ និងត្រូវលាងសម្អាតជម្រះចេញក្នុងឆ្នាំថ្មីនេះ

ដែលជាទំនៀមមួយមិនអាចចោលបាននូវក្នុងវប្បធម៌ប្រពៃណីខ្មែរ ដែលទាក់ទងនឹងកិច្ចពិធីស្រង់ព្រះពុទ្ធអង្គ និងស្រង់ព្រះរស់ដែលជាឪពុកម្ដាយ ជីដូនជីតារបស់យើងផងដែរ។

ល្បែងប្រជាប្រិយខ្មែរ បានកកើតឡើងតាមរយៈជីវភាពប្រចាំថ្ងៃនៃប្រជាពលរដ្ឋខ្មែរតាមសម័យកាលនីមួយៗ ពោលគឺមានប្រភពចេញពីកម្លាំងពលកម្ម ការរស់នៅប្រចាំថ្ងៃរបស់ប្រជាពលរដ្ឋ និងជាការចេះចាំតៗគ្នា។ ដោយនៅរយៈពេលប៉ុន្មានថ្ងៃខាងមុខនេះ ប្រទេសកម្ពុជានឹងរៀបចំនូវពិធីបុណ្យចូលឆ្នាំថ្មី ប្រពៃណីជាតិ ខ្មែរ ដែលក្នុងនោះប្រមុខរាជរដ្ឋាភិបាលកម្ពុជា បានជំរុញលើកទឹកចិត្តឱ្យគ្រប់បណ្ដាខេត្ត-រាជធានី ដឹកនាំពលរដ្ឋ ឱ្យលេងល្បែងប្រជាប្រិយខ្មែរ ដើម្បីការពារ ថែរក្សា វប្បធម៌ប្រពៃណីដូនតាខ្មែរ។

. **ល្បែងឈូង** ជាល្បែងម្យ៉ាងរបស់មនុស្សប្រុសស្រីទូទាំងកម្ពុជរដ្ឋនិយមលេង ហើយគេតែងលេងនៅពេលយប់ ខែភ្លឺ ក្នុងរដូវចូលឆ្នាំថ្មី (ខែចេត្រ ពិសាខ)។ គេចែកគ្នាជា ២ ក្រុម គឺប្រុស១ក្រុម និងស្រី១ក្រុម។ ក្នុង១ក្រុមៗ មានគ្នាចំនួនពី១០នាក់ ឬ២០នាក់ឡើងទៅ ដោយឈរត្រៀមជា២ជួរ ទល់មុខគ្នា ឃ្លាតពីគ្នាប្រមាណជា៨ ឬ១០ ម៉ែត្រ។ គេយកក្រមា ឬកន្សែងមកធ្វូលឱ្យមូល ចងរិតឱ្យតឹងណែនល្អ ទុកឱ្យមានកន្ទុយបន្តិចហៅថា «ឈូង» សម្រាប់កាន់បោះ ឬចោលទៅមករកគ្នា។ ឈូងមាន ២បែប គឺឈូងច្រៀងរាំ និងឈូងលោះខ្ញុំ។ ល្បែងនេះគេលេងដើម្បីហាត់ភ្នែកឱ្យវៃ ដៃឱ្យរហ័ស តម្រង់ឱ្យត្រង់ ឱ្យមានស្មារតីប្រុងប្រយ័ត្ន ហាត់ទម្លាប់ខ្លួនឱ្យចេះប្រុងស្មារតី។

. **ល្បែងបោះអង្គុញ** គឺជាល្បែងមួយដែលគេឱ្យឈ្មោះទៅតាមវត្ថុដែលគេយកមកលេង គឺផ្លែអង្គុញដែលក្រៀមស្ងួត។ ល្បែងនេះ គេលេងបានទាំងប្រុសទាំងស្រី ទាំងចាស់ទាំងក្មេង នៅវេលាថ្ងៃ ឬយប់ខែភ្លឺ នារដូវចូលឆ្នាំ។ ល្បែងនេះ គេលេងបានចាប់ពីគ្នា២នាក់ឡើងទៅ រហូតដល់១០នាក់ ដោយចែកចេញជាពីរក្រុមមានចំនួនស្មើគ្នា។ អង្គុញដែលគេយកមកលេង គេឱ្យឈ្មោះថា កោយ ដែលចែកចេញជាពីរផ្នែក គឺកោយដាំ និងកោយបោះ។ បើកោយដាំនោះមានចំនួន៣ ឬចំនួន៥ គឺថាកោយបោះក៏មានចំនួនតាមកោយដាំដែរ និងអាស្រ័យលើអ្នកលេង មានតិច ឬច្រើន។ លុះសន្មត់គ្នាហើយ ក្រុមនីមួយៗក៏នាំគ្នាបោះអង្គុញតម្រង់ទៅកោយដែលដាំឱ្យត្រូវ។ ក្រុមណាបោះត្រូវច្រើនជាង ក្រុមនោះគឺជាអ្នកឈ្នះ ហើយអ្នកឈ្នះគេយកអង្គុញពីរមកដាក់ផ្ដោបគ្នាដោយ ដាក់អង្គុញមួយផ្ដេក ១ ទៀតបញ្ឈរ ទុកចន្លោះឱ្យឃ្លាតគ្នាបន្តិចដើម្បីជួសទៅនឹងជង្គង់អ្នកចាញ់ឱ្យឮ បើជួសមិនឮ នោះអ្នកចាញ់មានសិទ្ធិជួសអ្នកឈ្នះវិញ។

.**ល្បែងលាក់កន្សែង** ជាល្បែងម្យ៉ាង របស់ក្មេងខ្មែរក្នុងបុរាណកាល តែងលេងសម្រាប់ជាទីកម្សាន្តសប្បាយនៅពេលរាត្រីខែភ្លឺ ក្នុងរដូវចូលឆ្នាំ ឬនៅពេលចន្លោះការហាត់ទៀយម្តងៗ។ មុនដំបូង គេបបួលគ្នាបានចំនួនពី ៦-៧ នាក់ឡើងទៅ ឱ្យអង្គុយច្រហោង ជំកង់ជារង្វង់មូល ដាក់ដៃទាំងពីរទៅមុខលើក្បាលជង្គង់ នាទីកន្លែងណាមួយ ដែលជាទីស្រឡះរាបស្មើល្អ ហើយគេយកកន្សែង ឬក្រមាតូចមួយមករុំមូរធ្វលរឹតឱ្យតឹងណែនល្អ ទុកជាយបន្តិចសម្រាប់កាន់យួរបាន សន្មតហៅថា «កន្សែង» ដោយមានម្នាក់ក្រោកចេញទៅក្រៅរង្វង់ កាន់កន្សែងនោះ ដើរព័ទ្ធជុំវិញយ៉ាងលឿនពីខាងក្រោយខ្នងអ្នកអង្គុយ បញ្ឆោតអ្នកអង្គុយមិនឱ្យដឹងខ្លួនថាគេលាក់កន្សែងក្រោយខ្នងអ្នកណាម្នាក់ទេ ហើយអ្នកដែលត្រូវគេដាក់កន្សែងនោះ បើបានដឹងហើយ ត្រូវតែក្រោកឡើងឱ្យរវាសដេញវាយអ្នកអង្គុយបន្ទាប់ ហើយអ្នកអង្គុយបន្ទាប់នោះត្រូវក្រោករត់១ជុំ គេចពីការដេញវាយនោះ មកអង្គុយកន្លែងខ្លួនវិញ ទើបអ្នកវាយនោះដើរលាក់កន្សែងជាបន្ត។

. **ល្បែងទាញព្រ័ត្រ** ជាល្បែងលេងកម្សាន្តសប្បាយរបស់យុវជនខ្មែរទាំងបុរស ទាំងស្ត្រី។ ល្បែងនេះគេលេងដោយប្រើកម្លាំងកាយ ហើយគេលេងតែក្នុងរដូវចូលឆ្នាំខ្មែរ គឺខែចេត្រ ពិសាខប៉ុណ្ណោះ។ មុនដំបូងគេចែកអ្នកលេងជា២ក្រុម ១ក្រុមពី១០ទៅ២០នាក់ ដោយរើសរកប្រុសម្នាក់ ស្រីម្នាក់ មានមាឌធំមាំ កម្លាំងខ្លាំង ឱ្យជាអ្នកឈរកាន់ចុងព្រ័ត្រ គឺប្រុសកាន់ម្ខាង ស្រីកាន់ម្ខាង ហើយឱ្យប្រុសម្នាក់ ស្រីម្នាក់ទៀតមានមាឌធំ មានកម្លាំងឈរកណ្តាលព្រ័ត្រ ត្រង់កន្លែងដែលពួកទាំងពីរឈរ សម្រាប់នាំពួកខ្លួនឱ្យខំទាញតែរៀងខ្លួន ឯមនុស្សដែលមានមាឌតូចៗស្គមៗ កម្លាំងខ្សោយៗ គេឱ្យឈរកណ្តាលគេ។ លុះរៀបចំរួចហើយ គេឱ្យមនុស្សប្រុសម្នាក់កាន់សំភោរ ឬគងម៉ង់ ឬក៏រគាំងឈរត្រង់កណ្តាលទីជិតអ្នកទាំងពីរដែលកាន់ខ្សែឈរប្រទល់មុខគ្នានោះ ផ្តើមស្រែកឡើងព្រមគ្នាថា **យក្សអរ**!.! ឮយ៉ាងខ្លាំងៗ ធ្វើសំឡេងវែងៗ រលាក់រលែកយ៉ាងគ្រលួចៗ ឯអ្នកប្រុងទាញព្រ័ត្រទាំងប៉ុន្មានជួយស្រែកទទួលឡើងព្រមគ្នា ហ៊ោ៣ដង ទើបនាំគ្នាទាញយកជ័យជម្នះរៀងៗខ្លួន។

. **របាំត្រុដិ**

របាំត្រុដិ ជារបាំមួយដែលគេរាំក្នុងពេលចូលឆ្នាំ ដែលកើតឡើងពីជនជាតិសំរែ ដែលជាជនជាតិដើមមួយនៅលើទឹកដីយើងក្នុងអំបូរខ្មែរ-មន។ ជនជាតិសំរែរស់នៅត្រង់ម្តុំក្បែរអង្គរ ខេត្តសៀមរាប។ របាំត្រុដិផ្សារភ្ជាប់នឹងជំនឿបន់ស្រន់ទឹកភ្លៀង។ ក្នុងរបាំនេះ គេនិយមប្រើកន្ទុយក្ងោក ដែលគេយល់ថា ក្ងោក

ជាតំណាងព្រះអាទិត្យ។ មនុស្សបន់ស្រន់អង្វរកព្រះអាទិត្យឱ្យធ្វើអំណោយទឹកភ្លៀងគ្រប់គ្រាន់សម្រាប់ធ្វើស្រែចម្ការ។ នៅពេលគ្មានភ្លៀងធ្លាក់ គេលេងត្រុដិសុំទឹកភ្លៀង។ របាំត្រុដិលេងនៅពេលចូលឆ្នាំ គឺគេលេងថ្វាយព្រះអាទិត្យអង្វរកឱ្យហើយស្រេចតាំងពីដើមឆ្នាំទៅ សុំទឹកភ្លៀងសម្រាប់វស្សារដូវខាងមុខនេះ។

ពាក្យថា **ត្រុស្តិ** ក្លាយមកពីភាសាសំស្ក្រឹតថា **ត្រុដ** កិ. "**កាត់ ផ្តាច់**" ត្រុដិ ន. "**ដំណើរកាត់ ការផ្តាច់**" ក្នុងព្រះរាជពិធីនេះ សំដៅយកសេចក្តីថា "**ដំណើរផ្តាច់ឆ្នាំចាស់ ផ្លាស់ចូលឆ្នាំថ្មី**។

ប្រភព របាំត្រុដិជារបាំមួយកើតឡើងពីជនជាតិសំរែ ដែលជាជនជាតិដើមមួយផ្នែកនៅលើទឹកដីយើងក្នុងអំបូរខ្មែរ-មន។ ជនជាតិសំរែរស់នៅត្រង់ម្តុំក្បែរអង្គរ ខេត្តសៀមរាប។

របាំត្រុដិផ្សារភ្ជាប់នឹងជំនឿបន់ស្រន់ទឹកភ្លៀង។ ក្នុងរបាំនេះគេនិយមប្រើកន្ទុយក្ងោក ដែលគេយល់ថា ក្ងោកជាតំណាងព្រះអាទិត្យ។ មនុស្សបន់ស្រន់អង្វរកព្រះអាទិត្យឱ្យធ្វើអំណោយទឹកភ្លៀងគ្រប់ គ្រាន់សម្រាប់ធ្វើស្រែចម្ការ។ នៅពេលគ្មានភ្លៀងធ្លាក់គេលេងត្រុដិសុំទឹកភ្លៀង។ របាំត្រុដិលេងនៅពេលចូលឆ្នាំគឺគេលេងថ្វាយព្រះអាទិត្យអង្វរឱ្យហើយស្រេចតាំងពីដើមឆ្នាំទៅសុំទឹកភ្លៀងសម្រាប់វស្សានរដូវខាងមុខ។

ការរាំរបាំត្រុដិនាពេលចូលឆ្នាំថ្មី គឺគេកំណត់យកដំណើរផ្តាច់ឆ្នាំនីមួយៗដើម្បីដេញឧបទ្រពចង្រៃដែលកើតមានក្នុងឆ្នាំចាស់ ហើយនិងប្រសិទ្ធពរសព្ទសាធុការក្នុងឱកាសឆ្នាំថ្មីវិញ។ តាមរយៈការសម្តែងគឺប្រជាពលរដ្ឋយើងតែងតែមានសេចក្តីសប្បាយរីករាយណាស់ព្រោះអ្នករាំរបាំត្រុដិបានចូលទៅដល់មុខផ្ទះឬក្នុងភូមិ ខណៈពេលដែលពួកគាត់មានជំនឿប្រកបដោយក្តីសង្ឃឹមថាក្នុងឆ្នាំថ្មីនេះសុភមង្គលលាភសក្ការៈ នឹងកើតមានក្នុងក្រុមគ្រួសារឬភូមិស្រុករបស់គាត់មិនខាន។ ជាទូទៅគេសម្តែងរបាំត្រុដិនេះពាសពេញភូមិតែម្តង ប្រសិនបើជាមានសត្វព្រៃរត់ចូលភូមិស្រុករបស់គេ ព្រោះគេមានជំនឿថា ពេលណាមានសត្វព្រៃដូចជាឈ្លូស ប្រើស រមាំងជាដើម រត់ចូលភូមិក្នុងករណីណាក៏ដោយពួកគេនឹងចាត់ទុកថានោះគឺជាអព្វតហូតហេតុអាក្រក់ឬចង្រៃ ហើយត្រូវអញ្ជើញក្រុមរបាំត្រុដិមកលេងដើម្បីបណ្តេញភាពចង្រៃនោះចេញ។ ប៉ុន្តែប្រសិនបើគេចាប់បានពពួកសត្វព្រៃនោះវិញ គឺគេយកវាទៅលាបប្រេងម្សៅ ហើយធ្វើពិធីលែងឱ្យមានសេរីភាពវិញដោយបួងសួងសុំសេចក្តីសុខសប្បាយប្រជាពលរដ្ឋក្នុងភូមិ ស្រុក ពេលដែលគេមានជំនឿ

ថា សត្វព្រៃទាំងនោះបានមករំដោះគ្រោះមហន្តរាយដល់ពួកគេ។

**ឧបករណ៍សម្តែង**

**- ឧបករណ៍តន្ត្រី**

**កញ្ជារ៖** ដងធ្វើពីពីងពង់ប្រវែង២ម៉ែត្រ មានបន្ទះរនាបតូចភ្ជាប់នៅចុង ហើយខ្វែងពីចុងមួយ ទៅចុងមួយ ហើយត្រង់កណ្តាលខ្សែខ្វែងនេះមានបន្ទោងផ្ទៃអង្កុញ ដែលចោះយកគ្រាប់ចេញអស់ ហើយដាក់គ្រាប់គ្រួស ឬដែកទៅក្នុងនោះ ប្រយោជន៍ឱ្យឮសូរ កាលណាគេបុកដងវានឹងដីតាមចង្វាក់ស្គរ។

**ចង្រង់ដំបែ៖** ចង្រង់បន្តោងនឹងខ្សែទាមគោហើយចងភ្ជាប់ដងឫស្សីដែរ។ កាលណាគេបុកនឹងដី ក៏លាន់សូរប្រាវៗតាមចង្វាក់។

**ចង្រង់រ៉ូង៖** ចង្រង់នេះចងព្យួរនឹងចង្កេះមនុស្សតែម្តង ដោយចងគួបជាចង្កោមៗ។

**ស្គរ៖** ស្គរធ្វើពីដីដុតពាសស្បែកថ្ពាន់។

**ប៉ីពក ទ្រអ៊ូ ទ្រសោ។**

**សន្ទូច៖** ដងពីងពង់វែងមានសណ្ឋានដូចសន្ទូច ចុងដូចចន្ទោលរទេះ ដោយមានព្យួរចង់មួយនៅចុង សម្រាប់ទទួលវត្ថុជាទាន។

**- ឧបរណ៍តែង**

**មុខត្លុក៖** ធ្វើពីធ្លីងឫស្សី ពាសក្រដាស ឬ ស្នាច់ ឬ ខ្នុក។

**មកុដ៖** ធ្វើពីក្រដាសលាបការ និងបិទឱ្យតម្រូវគ្នាទៅជារឹង គឺស្នាច់ ឬ ខ្នុក ហើយផាត់ពណ៌។

ស្នែងប្រើសស្នែងទន្សោងកន្ទុយក្ងោក។

**ក្របក៖** យកផ្តៅប្រវែង០,២ម៉ែត្រ បិតចុងឱ្យស្រួច រោលភ្លើងឱ្យង យកអំបោះចងគល់ភ្ជាប់នឹងម្រាម៤ ឯមេដៃមិនពាក់ទេ។

**+ តួសម្តែង**

- អ្នកពាក់មុខខ្មៅ ធ្វើមនុស្សព្រៃ
- អ្នកពាក់មុខត្លុក ធ្វើព្រានព្រៃ
- អ្នកពាក់ស្នែងប្រើស ស្នែងទន្សោង
- តួរាំ (តួឯក តួនាង)
- អ្នកពាក់ក្របក
- អ្នកកាន់គ្រឿងភ្លេង

តួសម្តែងក្នុងរបាំត្រុដិជាមធ្យមមានម្ភៃប្រាំនាក់។

**+ របៀបសម្តែង**

- ដំបូងបង្អស់តួសំដែងទាំងអស់ត្រូវបន្ទន់កាយរំលឹកគុណគ្រូ។ អ្នកពាក់មុខទាំងអស់(មនុស្សព្រៃ ព្រានព្រៃ) ចេញមកមានកិរិយាមិននឹងធឹងច្រើនរត់រឆ្វេងស្តាំ ចេញក្រៅពីវង់ ហើយច្រើនរត់ទៅមុខគេ។ ដងខ្លួនធ្វើផេកផោកយោលទៅតាមចង្វាក់ស្គរ ដៃគ្រាន់តែពត់បន្តិចមិនពេញជារាំទេ។ តួព្រានស្លៀកស្លឹកចេកច្រៀក ចងព័ទ្ធចង្កេះ លាបខ្លួនខ្មៅ។

អ្នកពាក់ស្នែង (ប្រើស ទន្សោង) ចាក់ក្បាច់ប្រហែលព្រាននិងមនុស្សព្រៃដែរ។ ដៃទាំងពីរជូនយកទៅកាន់ស្នែង ជូនលូកទៅមុខ ទំនងធ្វើជាដើងម្រឹគ ដោយឱ្យបង្អោងខ្លួន។ គេរាំលោតៗតាមចង្វាក់ ស្គរផ្អៀងផ្អងដូចម្រឹគផ្អើលម្តងៗ។ យូរៗប្រើសនិងទន្សោងធ្វើជារត់ចេញខាងក្រៅវង់ម្តងៗដែរ។

តួឯក និង តួនាងច្រើនជាតួរាំនារី។ តួឯកពីរនាក់ស្លៀកចង់ក្បិនពណ៌ ពាក់អាវពណ៌ ពាក់របៃ គ្មានសង្វារ ហើយបង់កន្សែងពណ៌សំយុង។ តួរាំពីរគូនេះ មានក្បាច់ទន់ភ្លន់ជាងគេ ដោយមានឫកជានារីក្រមុំអែនអន កែក្រាយ។

អ្នកពាក់ក្រចក និង អ្នកកាន់គ្រឿងភ្លេង ជាតួបន្ទាប់បន្សំ។ អ្នកពាក់ក្រចកជួយច្រៀង និង ឱ្យចង្វាក់ជួយបង្កើនទស្សនីយភាពនៃវង់របាំ។ អ្នកកាន់គ្រឿងភ្លេង ជាពិសេសអ្នកបុកកញ្ជារ និង អ្នកកាន់ចង្រ្កង់ដំបែជួយចង្វាក់ស្គរ និង យោលខ្លួនចុះឡើងតាមចង្វាក់ស្គរ និង កញ្ជារ។

**+ ទំនុកច្រៀង**

*ហាអើយ វង់ត្រុដិស្រុកអាយ វង់ត្រុដិស្រុកអាយ លំឱនអង្គកាយ សូមពរឆ្នាំថ្មី។*

*បន្ទរ៖ ឱណា នាងណា សូមពរឆ្នាំថ្មី!*

*ហាអើយ ផ្គរលាន់ឯត្បូង ត្រយូងចេកផ្កា អ្នកអើយត្រុដិលា ឈប់លេងត្រឹមណោះ។*

*បន្ទរ ៖ ឱណានាងណា ឈប់លេងត្រឹមណោះ!*[២]

កំណត់សម្គាល់៖ ចំពោះទំនុកច្រៀងទោះបីមានគំលាតពីន័យដើមពីសំណូមពរសុំទឹកភ្លៀង ក៏យើងឃើញទំនុកច្រៀងក្នុងរបាំនេះនៅមានសំណល់ជាតុខ្លះដែលមានក្នុងអាជីវកម្ម កសិកម្ម គឺបញ្ហាទឹក។ យើងយល់ថា របាំត្រុដិត្រូវបានជនជាតិសំរែប្រើប្រាស់សម្រាប់ដោះស្រាយសំណូមពរកសិកម្មដើម្បីទ្រទ្រង់ជីវិតរស់នៅ។ ប៉ុន្តែឆ្លងកាត់ដំណាក់កាលវិវត្តនៃប្រវត្តិសាស្ត្រសង្គមមនុស្ស របាំត្រុដិត្រូវបានទទួលឥទ្ធិពលខ្លាំងពីសាសនា ហើយត្រូវបានគេយកមកប្រើក្នុងបំណងផ្សេងទៅវិញ។

ចំពោះការសម្តែងរបាំត្រុដិនៅតាមភូមិណិមួយៗកាលពីសម័យដើមវិញ គឺមានការតុបតែងខ្លួនជាលក្ខណៈសាមញ្ញ ហើយគេដើរដង្ហែជាក្បួនទៅមុខ ដោយមានអ្នកកាន់ដងចន្ទោលដែលមានការចងកំណាត់លម្អ

[២] ពេលខ្លះក៏ច្រៀងខុសពីទំនុកនេះខ្លះដែរ អាស្រ័យទៅតាមការកាឡៃនៃក្រុមសម្តែង។

និងមានសិល្បករម្នាក់ជាអ្នករាំនាំផ្លូវផង។ តាមអ្វីដែលយើងបានឃើញពិធីរាំនោះ គឺមើលទៅហាក់ដូចជាអ្នករាំ ឬអ្នកហែទាំងនោះកំពុងតែជិះលើរទេះមួយដូច្នេះដែរ។ ចំណែកនៅខាងចុងនៃដងចន្ទោលនោះ មានចងកូនថង់មួសម្រាប់ជាការរែអង្គាសប្រាក់ ហើយអ្នកផ្ទះឬអ្នកភូមិ ដែលមកឈរមើលការរាំរបាំត្រុដិនិងមានសទ្ធាជ្រះថ្លា ពួកគេនឹងដាក់ប្រាក់ក្នុងថង់នោះ ព្រោះគេមានជំនឿថា បុណ្យកុសលដែលបានដាក់ទាននាពេលនេះ នឹងបានចម្លងគ្រោះកាចចង្រៃនៃឆ្នាំចាស់ទៅអស់ ហើយចូលឆ្នាំថ្មីសិរីសួស្តីសុភមង្គលនឹងមកដល់។

ជាសរុបសេចក្តីទៅពិធីបុណ្យចូលឆ្នាំជាពិធីបុណ្យមួយដែលល្អនៅក្នុងប្រពៃណីខ្មែរ ជាពិធីបុណ្យផ្តាច់ឆ្នាំចាស់ផ្លាស់ឆ្នាំថ្មី ជាពិធីបុណ្យនៃការវិលមកត្រលប់ជួបជុំគ្នា សួរសុខទុក្ខគ្នា ដើម្បីទទួលទេវតាឆ្នាំថ្មីឆ្នាំថ្មី បួងសួងសុំពរជ័យសិរីមង្គលវិបុលសុខ និងជាប្រពៃណីបណ្តុះនូវស្មារតីស្រឡាញ់រាប់អានគ្នាមិនត្រឹមតែជាបងប្អូនសាច់ញាតិ គឺរវាងអ្នកភូមិស្រុកជិតខាងគ្នា ដែលជាកត្តាបង្កើតសាមគ្គីភាពជាតិផងដែរ ដ្បិតពេលចូលឆ្នាំ គេមិនត្រឹមតែជួបជុំគ្នាក្នុងគ្រួសារប៉ុណ្ណោះទេ តែគេនាំគ្នាទៅធ្វើបុណ្យនៅវត្តអារាម ដែលជាមជ្ឈមណ្ឌលអប់រំឱ្យមានមនុស្សធម៌ និងសាមគ្គីធម៌។ ហេតុដូច្នេះហើយ ទើបពិធីបុណ្យចូលឆ្នាំថ្មី មានអត្ថន័យយ៉ាងជ្រាលជ្រៅ ដែលធ្វើឱ្យខ្មែរយើងនិយមរាប់អានទុកជា ប្រពៃណីជាតិតាំងពីដើមរហូតមកដល់បច្ចុប្បន្នយើងនេះ។

ក្នុងនាមនាងខ្ញុំជាប្រជាពលរដ្ឋខ្មែរម្នាក់ នាងខ្ញុំសូមសំណូមពរឱ្យប្រជាជនខ្មែរទាំងអស់នាំគ្នាចូលរួមថែរក្សានូវប្រពៃណីនៃពិធីបុណ្យចូលឆ្នាំប្រពៃណីខ្មែរឱ្យបានគង់វង់ និងអភិរក្សនូវរាល់ល្បែងក៏ដូចជារបាំប្រជាប្រិយខ្មែរដែលមាន ដើម្បីបន្តនូវមរតកល្បែងទាំងនេះទុកឱ្យកូនចៅខ្មែរជំនាន់ក្រោយៗទៀត បានស្វែងយល់ បានលេងកម្សាន្ត ដ្បិតល្បែងប្រជាប្រិយទាំងនេះ មិនត្រឹមតែនាំមកនូវភាពសប្បាយរីករាយប៉ុណ្ណោះទេ គឺបានបង្កប់នូវអត្ថន័យនិងគោលបំណងច្បាស់លាស់សម្រាប់កូនចៅខ្មែរដូចជាឱ្យមានសាមគ្គីភាព មិត្តភាព ស្រឡាញ់រាប់អានគ្នា មានទឹកចិត្តក្លាហាន ទន់ភ្លន់តែមិនទន់ជ្រាយ រហ័សរហួន ឈ្លាសវៃ និងដើម្បីពង្រឹងកាយសម្បទាឱ្យរឹងមាំជាដើម ហើយអ្វីដែលពិសេសនិងមានតម្លៃមិនអាចកាត់ថ្លៃបាននោះ គឺជាមរតកវប្បធម៌ នៃប្រជាជាតិខ្មែរ ជាអត្តសញ្ញាណជាតិខ្មែរតាំងពីយូរលង់ណាស់មកហើយ៕

# ឯកសារពិគ្រោះ


- ក្រសួងអប់រំ *អក្សរសិល្ប៍ថ្នាក់ទី១០* ភ្នំពេញ ឆ្នាំ១៩៩៧-៩៨។
- ខឹម សំឱ *មូលដ្ឋានស្វែងយល់អក្សរសាស្ត្រខ្មែរ* ភ្នំពេញ ឆ្នាំ១៩៦៣។
. ជា វណ្ណិ & ទុយ យូឃីម *អក្សរសិល្ប៍ប្រជាប្រិយខ្មែរ* ឆ្នាំ២០១៧។
- ពុទ្ធសាសនបណ្ឌិត្យ *ប្រជុំរឿងព្រេងខ្មែរ* ភាគ១ដល់៩ ភ្នំពេញ ឆ្នាំ១៩៩៤។
- ពុទ្ធសាសនបណ្ឌិត្យ *ល្បែងប្រជាប្រិយខ្មែរ* ភ្នំពេញ ឆ្នាំ១៩៩៤។
- ពុទ្ធសាសនបណ្ឌិត្យ *របាំប្រជាប្រិយខ្មែរ* ភ្នំពេញ ឆ្នាំ១៩៩៤។
- ពុទ្ធសាសនបណ្ឌិត្យ *ពិធីបុណ្យទ្វារទសមាស* ភ្នំពេញ ឆ្នាំ១៩៩៤។
- ពៅ សាមី *លក្ខណៈពិសេសនៃអក្សរសិល្ប៍ និងសិល្បៈ* ភ្នំពេញ ឆ្នាំ១៩៩២។
- ហ៊ុន គឹមសៀ *មូលដ្ឋានដើម្បីយល់អក្សរសាស្ត្រ* គ្រឹះស្ថានបោះពុម្ពផ្សាយអប់រំ ១៩៥៨។